# ជំនាញឌីជីថល

សព្វថ្ងៃនេះ បច្ចេកវិទ្យាគឺជាផ្នែកដ៏សំខាន់មួយនៃជីវិតរបស់យើងដែលពុំអាចខ្វះបាន ហើយការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាទាំងនេះបានបង្កើតនូវជំនាញថ្មីៗជាច្រើន និងបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើគ្រប់វិស័យ រួមទាំងរបៀបរបបនៃការរស់នៅ, ការបំពេញការងារ, ការធ្វើអាជីវកម្មដែលទាំងអស់នេះពឹងផ្អែកលើអ៊ីនធឺណិតស្ទើរតែទាំងស្រុង។ សម្រាប់វិស័យកសិកម្មយើងសង្កេតឃើញថា ការប្រមូលផលដោយដៃ ឬការដាំដុះដែលមានរយៈពេលយូរលែងជាបញ្ហាទៀតហើយ ដោយកសិករប្រើប្រាស់ឧបករណ៍ចាប់សញ្ញា និងបច្ចេកវិទ្យាអ៊ីនធឺណិតនៃវត្ថុ ដើម្បីធ្វើស្វ័យប្រវត្តិកម្ម ត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធកសិកម្មរបស់ពួកគេឱ្យកាន់តែទទួលបានផលចំណេញ ប្រសិទ្ធភាព និងនិរន្តរភាព។ ចំណែកឯវិស័យអចលនទ្រព្យ ដែលជាវិស័យមួយបែបប្រពៃណីក៏បានប្រែខ្លួនមកជាទម្រង់ឌីជីថល និងបានប្រើប្រាស់ជំនាញឌីជីថលផងដែរ។ ម្ចាស់អាជីវកម្មផ្នែកអចលទ្រព្យចាំបាច់ត្រូវយល់ច្បាស់ពីជំនាញឌីជីថល ដើម្បីសម្របខ្លួនទៅនឹងបរិបទឌីជីថល និងធ្វើទីផ្សារឱ្យចំគោលដៅ។ ជាឧទាហរណ៍ ការរចនាក្រាហ្វិកទៅលើផ្ទះនីមួយៗឱ្យមានភាពទាក់ទាញ និងការបង្កើតគេហទំព័រ ដើម្បីផ្សព្វផ្សាយជាដើម។ បន្ថែមពីនេះទៀត អាជីវកម្មជាច្រើនក៏បានទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ដើម្បីជួយឱ្យអាជីវកម្មរបស់ពួកគេតាមទាន់ទៅនឹងការវិវត្តរបស់បច្ចេកវិទ្យា ក៏ដូចជាបង្កើនការផលិត និងផ្តល់ភាពងាយស្រួលដល់អតិថិជន។ ជាឧទាហរណ៍ ការបង្កើត E-Menu ដាក់នៅលើគេហទំព័ររបស់អាជីវកម្ម និងការដាក់ Menu របស់ខ្លួនទៅក្នុងកម្មវិធីដឹកជញ្ជូនជាដើម។ ការរីកចម្រើននៃបច្ចេកវិទ្យា និងកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាប៉ុន្មានឆ្នាំចុងក្រោយនេះបានជំរុញឱ្យមានតម្រូវការជំនាញឌីជីថលកាន់តែច្រើន ដើម្បីបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារ, ការសិក្សា ក៏ដូចជាអាជីវកម្មផងដែរ។ ដោយឡែក យោងតាមគេហទំព័រ **World Economic Forum** រំពឹងថា២០២៥ និយោជិតនៅទូទាំងសកលលោកប្រមាណជា **៥0%** នឹងត្រូវការការបណ្តុះបណ្តាលជំនាញបន្ថែម និងបង្កើនជំនាញថ្មី (Reskilling and Upskilling) ដើម្បីបំពេញតម្រូវការការងារ ទីផ្សារការងារ ក៏ដូចជាដើរឱ្យទាន់បរិបទ និងនិន្នាការថ្មីៗនៅក្នុងសង្គមផងដែរ។ ការណ៍នេះ បង្ហាញថាជំនាញឌីជីថលបានក្លាយជាភាពចាំបាច់ និងពុំគួរមើលរំលង។

**ជំនាញឌីជីថល** សំដៅដល់សមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ទំនាក់ទំនង កម្មវិធីទំនាក់ទំនង និងបណ្តាញសង្គមជាដើម ដើម្បីអាចចូលទៅប្រើប្រាស់ទិន្នន័យ និងគ្រប់គ្រងព័ត៌មាន។ ជំនាញនេះផ្តល់នូវសិទ្ធចូលប្រើប្រាស់ ដើម្បីបង្កើត និងចែករំលែកមាតិកាឌីជីថល, ទំនាក់ទំនងនិងសហការ, ដោះស្រាយបញ្ហា និងបង្កើនភាពច្នៃប្រឌិតក្នុងជីវិតរួមទាំងការសិក្សា, ការងារ, អាជីវកម្ម និងសកម្មភាពសង្គមផ្សេងៗជាដើម។

ជំនាញឌីជីថលត្រូវបានបែងចែកជា ៣ កម្រិតដូចជា៖

### ជំនាញឌីជីថលកម្រិតមូលដ្ឋាន

- ការប្រើប្រាស់អ៊ីនធឺណិតឱ្យមានប្រសិទ្ធភាព, សុវត្ថិភាព និងមានទំនួលខុសត្រូវខ្ពស់
- ជំនាញរដ្ឋបាល ដូចជា ការសរសេរ, ការរៀបចំឯកសារ, ការចងក្រងទិន្នន័យ និងការរៀបចំបទបង្ហាញ ជាដើម
- ជំនាញក្នុងការប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការទំនាក់ទំនងដូចជា Telegram, Messenger, Line និង Twitter ជាដើម
- ការប្រើប្រាស់បច្ចេកវិទ្យាក្លោដ ដើម្បីរក្សាទុកឯកសារលើ Google-Drive និង Drop Box ជាដើម

### ជំនាញឌីជីថលកម្រិតមធ្យម

- ជំនាញបណ្ដាញសង្គម Facebook, Instagram, YouTube និង TikTok ជាដើម
- ជំនាញក្នុងការធ្វើទីផ្សារតាមបែបឌីជីថលលើបណ្ដាញសង្គម, ការធ្វើទីផ្សារតាមរយៈមាតិកា និងការបង្កើនប្រសិទ្ធភាពនៃម៉ាស៊ីនស្វែងរក
- ជំនាញក្នុងការសរសេរស្វែងរកព័ត៌មាន
- ជំនាញរចនាក្រាហ្វិក
- ជំនាញផលិតវីដេអូ

### ជំនាញឌីជីថលកម្រិតខ្ពស់

- ជំនាញក្នុងការគ្រប់គ្រងទិន្នន័យ វិភាគ និងបកស្រាយទិន្នន័យ
- ជំនាញសហគ្រិនឌីជីថល
- ការធ្វើគេហទំព័រ (Website) និងកម្មវិធីទូរស័ព្ទ
- ជំនាញបច្ចេកទេសផ្នែក៖ បញ្ញាសិប្បនិម្មិត (AI), អ៊ីនធឺណិតនៃវត្ថុ (IoT), សន្តិសុខសាយប័រ (Cyber Security), ទិន្នន័យធំ (Big Data), ស្វ័យប្រវត្តិកម្ម (Automation), ប្រព័ន្ធកុំព្យូទ័រក្លោដ (Cloud Computing), Augmented Reality និង Virtual Reality។

## I. ហេតុផលសំខាន់ៗដែលធ្វើឱ្យតម្រូវការជំនាញឌីជីថលមានការកើនឡើង

ការវិវត្តយ៉ាងលឿនរបស់បច្ចេកវិទ្យា រួមទាំងការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ តម្រូវឱ្យយើងត្រូវធ្វើការសម្របខ្លួនទៅនឹងបរិបទថ្មីនេះ ដោយចាំបាច់ត្រូវចេះ និងមានជំនាញឌីជីថល ដើម្បីធ្វើការប្រកួតប្រជែងនៅក្នុងទីផ្សារការងារ។ ប្រសិនបើអ្នកពុំអាចចាប់យកជំនាញឌីជីថល អ្នកនឹងមិនបានរួមចំណែកនៅក្នុងសេដ្ឋកិច្ចឌីជីថលនាពេលបច្ចុប្បន្ននោះទេ ដោយហេតុថាការងារភាគច្រើនត្រូវបានប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។ យោងតាមគេហទំព័រ **High Speed Training** ឆ្នាំ២០២២ បានបង្ហាញថាបុគ្គលិកប្រមាណ **៥២%** ទូទាំងសកលលោកខ្វះជំនាញឌីជីថល ដែលជាហេតុនាំឱ្យមានការវិវត្តយឺត និងខ្វះគំនិតបង្កើតថ្មី។ ខាងក្រោមនេះនឹងបង្ហាញពីសារៈសំខាន់មួយចំនួននៃការដែលមានជំនាញឌីជីថល៖

## អត្រាទទួលបានការងារខ្ពស់

នាពេលបច្ចុប្បន្ននេះ ម្ចាស់អាជីវកម្ម និងក្រុមហ៊ុនតូច-ធំទាំងអស់ដឹងថាអតិថិជនរបស់ពួកគេស្ទើរតែទាំងស្រុង គឺស្ថិតនៅលើប្រព័ន្ធអ៊ីនធឺណិត ជាពិសេស នៅលើបណ្តាញសង្គម ដូចជា Facebook, Instagram និង TikTok ជាដើម។ ទាំងនេះជាមូលហេតុដែលធ្វើឱ្យមានការកើនឡើងនូវតម្រូវការអ្នកជំនាញក្នុងការគ្រប់គ្រង និងបង្កើតគេហទំព័រ, អ្នកជំនាញទីផ្សារឌីជីថល, អ្នកជំនាញផ្នែកកម្មវិធីទូរស័ព្ទ និងអ្នកបង្កើតមាតិកាជាដើម។ បន្ថែមពីនេះទៀត ការដែលមានជំនាញឌីជីថលមួយ ឬច្រើន អាចកំណត់ថាអ្នកខុសពីបេក្ខជនផ្សេងទៀតនៅក្នុងទីផ្សារការងារ ហើយជំនាញទាំងនេះនឹងធ្វើឱ្យអ្នកមានឱកាសទទួលបានការងារច្រើនជាងអ្នកដែលមិនមានជំនាញឌីជីថល បើទោះបីជាអ្នកមានបទពិសោធន៍ការងារប្រហាក់ប្រហែលគ្នាក៏ដោយ។

## ការទទួលបានការងារដែលមានប្រាក់ខែល្អ និងការរក្សានិរន្តរភាពការងារ

ក្នុងយុគសម័យឌីជីថលនេះ មិនថាស្ថាប័នរដ្ឋ ឬឯកជននោះទេ គឺកំពុងដំណើរការជាទម្រង់ឌីជីថលដែលជាហេតុធ្វើឱ្យជំនាញឌីជីថលទាំងអស់មានតម្រូវការយ៉ាងខ្លាំង។ ទន្ទឹមនេះ បណ្តាស្ថាប័នទាំងអស់ត្រូវការបុគ្គលិក ដែលមានសមត្ថភាពក្នុងការបំពេញតួនាទីថ្មីៗដែលទាក់ទងទៅនឹងបច្ចេកវិទ្យា ដែលនេះអាចជាបញ្ហាប្រឈមសម្រាប់បុគ្គលិកដែលមិនមានជំនាញឌីជីថល។ នៅក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ ការងារស្ទើរតែទាំងស្រុងបានងាកមកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងជាទម្រង់អនឡាញ ដើម្បីសម្របខ្លួនទៅនឹងបរិបទថ្មី ដែលតម្រូវឱ្យបុគ្គលិកទាំងអស់ត្រូវអភិវឌ្ឍន៍ខ្លួន និងផ្លាស់ប្តូរទម្លាប់ការធ្វើការងារបែបប្រពៃណី មកជាការប្រើប្រាស់បច្ចេកវិទ្យា និងជំនាញឌីជីថលវិញ។ ដោយឡែក បុគ្គលិកដែលមិនអាចសម្របខ្លួនបាន ឬមិនព្យាយាមចាប់យកជំនាញឌីជីថលនឹងអាចបាត់បង់ការងារ។ យោងតាមលោកស្រី **Simone Rennocks** ឆ្នាំ២០២២ បានបញ្ជាក់ថា ការដែលមានជំនាញឌីជីថលនឹងជួយកាត់បន្ថយហានិភ័យនៃការបាត់បង់ការងារបានប្រមាណ **៥៩%**។ ដូចនេះ ដើម្បីទទួលបាននូវការងារដែលមានប្រាក់ខែខ្ពស់ មានភាពលេចធ្លោនៅកន្លែងការងារ និងរក្សានូវស្ថិរភាពការងារដែលមានភាពប្រកួតប្រជែងនេះ យើងចាំបាច់ត្រូវមានជំនាញឌីជីថល និងចេះសម្របខ្លួនឱ្យបានឆាប់រហ័សទៅនឹងការវិវត្តរបស់បច្ចេកវិទ្យា។

## ការចាប់ផ្តើម និងការពង្រីកអាជីវកម្ម

ប្រសិនបើអ្នកជាម្ចាស់អាជីវកម្មខ្នាតតូច ហើយអ្នកនៅតែដំណើរការអាជីវកម្មរបស់អ្នកតាមរបៀបចាស់ទៀតនោះ អ្នកនឹងមិនអាចប្រកួតប្រជែងជាមួយដៃគូអាជីវកម្មរបស់អ្នកបានឡើយ។ នៅក្នុងយុគសម័យឌីជីថលនេះ មនុស្សមានភាពរវល់ច្រើន ដែលធ្វើឱ្យការដើរផ្សារដើម្បីទិញទំនិញត្រូវបានកាត់បន្ថយ និងជំនួសមកវិញ ដោយប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដើម្បីបញ្ជាទិញទំនិញដែលពួកគេចង់បាន ដូចនេះ មិនថាពួកគេនៅផ្ទះ ការិយាល័យ ឬទីជនបទ ក៏ពួកគេអាចទិញទំនិញបានដែរ។ អ្នកអាចប្រើជំនាញឌីជីថល ដូចជា ជំនាញក្នុងការធ្វើទីផ្សារតាមរយៈបណ្តាញសង្គម, ការបង្កើតមាតិកា ឬប្រើប្រាស់ SEO ដើម្បីឱ្យអតិថិជនរបស់អ្នកស្គាល់អំពីម៉ាកយីហោ, មុខទំនិញ និងមាតិកាផ្សេងៗដែលអ្នកចង់បង្ហាញ។

យើងអាចចាប់ផ្តើមអាជីវកម្មបានយ៉ាងងាយ ដោយប្រើប្រាស់ជំនាញឌីជីថលទាំងនេះ ហើយជំនាញទាំងនេះអាចជួយឱ្យយើងប្រើប្រាស់ធនធានតិច, ទទួលបានផលច្រើន និងមានហានិភ័យតិចតួចបំផុត។

## II. ជំនាញឌីជីថលសំខាន់ៗ

| ជំនាញ | និយមន័យ | រូបតំណាង |
|---|---|---|
| **ការធ្វើទីផ្សារបែបឌីជីថល** | សំដៅដល់ជំនាញក្នុងការធ្វើទីផ្សារ ដោយពឹងផ្អែកជាចម្បងលើប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយឌីជីថលផ្សេងៗ សម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងជាមួយគោលដៅអតិថិជន ដើម្បីផ្សព្វផ្សាយពីផលិតផល ឬសេវាកម្មរបស់ខ្លួន។ |  |
| **ការធ្វើទីផ្សារតាមរយៈមាតិកា** | គឺជាជំនាញស្នូលមួយ ដែលមិនអាចខ្វះបាននៅក្នុងការធ្វើទីផ្សារ ដោយហេតុថាមាតិកាអាចធ្វើឱ្យអតិថិជនដឹងពីម៉ាកយីហោ, បង្ហាញសកម្មភាពផ្សេងៗដែលទាក់ទងនឹងអាជីវកម្ម ឬការងារ, បង្កើតទំនុកចិត្ត និងទំនាក់ទំនងល្អជាមួយអតិថិជនផងដែរ។ ការធ្វើមាតិកាមានក្នុងទម្រង់ជាច្រើន ដូចជា៖ ការបង្ហោះ blog, ខ្លឹមសារ, សម្លេង, វីដេអូ, Podcast និង Infographic។ |  |
| **ការវិភាគទិន្នន័យ** | សំដៅដល់ជំនាញក្នុងការប្រមូលទិន្នន័យពីប្រភពផ្សេងៗគ្នា ហើយធ្វើការវិភាគ ដើម្បីស្វែងរកឫសគល់នៃបញ្ហា, មើលឃើញកាន់តែច្បាស់ពីឥរិយាបថនៃការចំណាយរបស់អ្នកប្រើប្រាស់ ជាពិសេសអាចកាត់បន្ថយហានិភ័យដែលអាជីវកម្ម ឬក្រុមហ៊ុននឹងប្រឈមផងដែរ។ |  |

| | | |
|---|---|---|
| **ការធ្វើទីផ្សារតាមម៉ាស៊ីនស្វែងរក** | គឺសំដៅដល់ការជំរុញការផ្សព្វផ្សាយពីផលិតផល និងសេវាកម្ម តាមរយៈម៉ាស៊ីនស្វែងរក ដូចជា Google, Yahoo និង Microsoft Bing ជាដើម។ អាជីវកម្មត្រូវការអ្នកដែលមានជំនាញនេះជាចាំបាច់ ដើម្បីឱ្យគេហទំព័ររបស់ពួកគេអាចលេចឡើងនៅលើគេ រាល់ពេលអតិថិជនស្វែងរកប្រភេទផលិតផល ឬសេវាកម្មដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ពួកគេ។ |   |
| **ការធ្វើទីផ្សារតាមរយៈសារអេឡិចត្រូនិក** | សំដៅដល់ការជូនដំណឹងពីផលិតផល និងសេវាកម្មទៅកាន់គោលដៅអតិថិជន តាមរយៈសារអេឡិចត្រូនិក ដោយធ្វើឡើងក្នុងពេលតែមួយ ហើយប្រកបដោយវិជ្ជាជីវៈ និងផ្តល់ទំនុកចិត្តខ្ពស់ដល់អតិថិជន ដែលជាហេតុធ្វើឱ្យមានតម្រូវការខ្ពស់សម្រាប់អ្នកមានជំនាញនេះ។ |  |
| **ការរចនាក្រាហ្វិក** | គឺជាសិល្បៈ ឬវិជ្ជាជីវៈ នៃការបង្ហាញដែលរួមបញ្ចូលរូបភាព, អក្សរ និងគំនិត ដើម្បីបញ្ជូនព័ត៌មានដល់ទស្សនិកជន។ អ្នករចនាក្រាហ្វិកអាចជូនដំណឹង ឬបញ្ចុះបញ្ចូលទស្សនិកជន តាមរយៈការប្រើប្រាស់រូបភាពដែលមានភាពច្នៃប្រឌិតរបស់ពួកគេ។ |   |
| **ការសរសេរកម្មវិធី (Programming)** | ជំនាញសរសេរកម្មវិធី សំដៅលើសមត្ថភាពក្នុងការប្រើប្រាស់ភាសាសរសេរកម្មវិធីផ្សេងៗ ដើម្បីសរសេរ commands, instructing a computer, កម្មវិធីទូរស័ព្ទ និង software ជាដើម។ ជំនាញនេះអាចប្រើសម្រាប់បង្កើតជាគេហទំព័រ, ហ្គេម, កម្មវិធីទូរស័ព្ទ និងកម្មវិធីកុំព្យូទ័រជាដើម។ |   |

| | | |
|---|---|---|
| **សហគ្រិនឌីជីថល** | សំដៅដល់ការផ្លាស់ប្ដូររបៀបធ្វើអាជីវកម្មរបស់សហគ្រាសឱ្យស្របតាមការវិវត្តនៃបច្ចេកវិទ្យាឌីជីថល ពិសេសការលក់ផលិតផល ឬសេវាកម្មតាមថ្នាលឌីជីថល និងការកែច្នៃផលិតផល ឬសេវាកម្មរបស់ខ្លួនបន្ថែមប្រកបដោយភាពច្នៃប្រឌិត។ |  |

## III. ករណីសិក្សាជំនាញឌីជីថលនៅកម្ពុជា

### ស្ថានភាពជំនាញឌីជីថលនៅកម្ពុជា

វិបត្តិជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមាន និងបានបង្កជាការរាំងស្ទះដល់ដំណើរការសេដ្ឋកិច្ច ដែលកត្តាទាំងនេះបានជំរុញឱ្យរដ្ឋាភិបាលកម្ពុជាគិតគូរនូវគំរូសេដ្ឋកិច្ចថ្មីៗ ដែលអាចឆ្លើយតបទៅនឹងការមកដល់នៃវិបត្តិ និងក្រោយវិបត្តិជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលបានមើលឃើញពីសក្តានុពល និងអត្ថប្រយោជន៏នៃវិស័យឌីជីថលក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច, បង្កើនផលិតភាពគ្រប់វិស័យ, បង្កើតការងារ និងធានានូវកំណើនសេដ្ឋកិច្ច។ ទោះជាក្នុងពេលវិបត្តិក្តី កម្ពុជា នៅតែបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ស្របនិងអំណោយផលផ្នែកប្រជាសាស្ត្រ ដែលកម្ពុជាមានប្រជាជនវ័យក្មេងច្រើន ដែលមានគោលគំនិតបើកចំហ ងាយក្នុងការទទួលយកផ្នត់គំនិតច្នៃប្រឌិត និងមានសមត្ថភាពគ្រប់គ្រាន់។ គិតត្រឹមឆ្នាំ**២០១៩** កម្ពុជាមានយុវជនដែលមានអាយុចន្លោះ **១៥ឆ្នាំ - ៣៥ឆ្នាំ** ប្រមាណជា **៥៦%** ដែលកត្តាប្រជាសាស្ត្រនេះបានក្លាយជាកត្តាដ៏សំខាន់មួយក្នុងការជួយជំរុញ និងចាប់យកនូវបរិវត្តកម្មឌីជីថល។ បន្ថែមពីនេះទៀត ស្របតាមកំណើនយ៉ាងឆាប់រហ័សនៃការប្រើប្រាស់ស្មាតហ្វូន, ឧបករណ៍ទូរគមនាគមន៍ និងប្រព័ន្ធអ៊ីនធឺណិត យើងក៏សង្កេតឃើញពីការកើនឡើងនៃចំនួនសិស្សានុសិស្ស និងបុគ្គលិកដែលមានសមត្ថភាពក្នុងការទាញយកអត្ថប្រយោជន៍ពីការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដែលទាំងអស់នេះជាកត្តាសំខាន់ក្នុងការរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។ យ៉ាងណាមិញ ជំនាញឌីជីថលក្នុងស្រុកហាក់ដូចជានៅមានកម្រិតនៅឡើយ ដោយហេតុថាមូលធនមនុស្សដែលមានទេពកោសល្យឌីជីថលនៅកម្ពុជាមានត្រឹមប្រមាណជា **៥០ ០០០នាក់** ខណៈដែលកម្លាំងពលកម្មក្នុងវិស័យឌីជីថលមានត្រឹមជំនាញកម្រិតមធ្យម ពុំទាន់មានលក្ខណៈប្រមូលផ្តុំ និងមិនមានភាពស៊ីជម្រៅ។ យោងតាមការអង្កេតរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ស្តីពី **"ភាពមិនស៊ីគ្នានៃជំនាញ និងគុណវឌ្ឍក្នុងប្រទេសកម្ពុជា" ភស្តុតាងពីការអង្កេតពីជំនាញ និងការងាររបស់កម្មករ-និយោជិតឆ្នាំ២០២០** បានបង្ហាញថា បុគ្គលិកប្រមាណជា **៨៣,៨%** បានលើកឡើងថាការងាររបស់ពួកគេទាមទារឱ្យពួកគេត្រូវមានជំនាញឌីជីថលដើម្បីបំពេញការងារ ក្នុងនោះ **៥០,២%** នៃការងារទាមទារជំនាញឌីជីថលកម្រិតមធ្យម ហើយ **៣៣,៥%** ទាមទារជំនាញឌីជីថលកម្រិតខ្ពស់ ទិន្នន័យខាងលើនេះបានបង្ហាញពីកំណើននៃតម្រូវការនូវជំនាញឌីជីថលក្នុងស្រុកក្នុងការបំពេញការងារ ខណៈដែលមូលធនមនុស្សដែលមានជំនាញឌីជីថលនៅ

មានកម្រិត។ បន្ថែមពីនេះទៀត តាមការសិក្សារបស់ **បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT)** ស្តីពី **«តម្រូវការ និងការផ្គត់ផ្គង់ជំនាញឌីជីថលនៅកម្ពុជា»** បានបង្ហាញថាកំណើននៃតម្រូវការជំនាញឌីជីថលក្នុងស្រុកនឹងមានការកើនឡើង, ក្នុងនោះការសិក្សាក៏បានបង្ហាញពីជំនាញឌីជីថលសំខាន់ៗមួយចំនួន ដូចជា ជំនាញផ្នែកលក់, ជំនាញ Software, ជំនាញក្នុងការវិភាគ និងបង្កើតមូលដ្ឋានទិន្នន័យ, ជំនាញរចនាក្រាហ្វិក, ជំនាញផ្នែកបច្ចេកវិទ្យាទំនាក់ទំនង និងជំនាញបច្ចេកទេសព័ត៌មានវិទ្យា។ ក្នុងនោះដែរ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយសំខាន់ៗ, យុទ្ធសាស្ត្រ និងការអនុវត្តគម្រោងនានា ដើម្បីលើកកម្ពស់ និងពង្រឹងជំនាញឌីជីថលនៅកម្ពុជា។

## ជំនាញសំខាន់ៗដែលយុវជននៅកម្ពុជាគួរចាប់យក

### ជំនាញឌីជីថលកម្រិតមូលដ្ឋាន

យោងតាមការលើកឡើងរបស់ **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រជាជនកម្ពុជាប្រហែល **៣០%** មានជំនាញឌីជីថលកម្រិតមូលដ្ឋាន និងមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល។ ផ្អែកលើទិន្នន័យនេះបង្ហាញថា យុវជនគួរចាប់ផ្តើមសិក្សាពីជំនាញឌីជីថលកម្រិតមូលដ្ឋាន ដូចជា ការចេះប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ,ម៉ាស៊ីនស្វែងរក, សារអេឡិចត្រូនិក និង កម្មវិធីរដ្ឋបាលសំខាន់ៗមួយចំនួន (Microsoft Word, Excel, PowerPoint, Outlook) ដែលជំនាញទាំងនេះសុទ្ធតែជាជំនាញចាំបាច់សម្រាប់ការងារប្រចាំថ្ងៃ និងអាចជាមូលដ្ឋានគ្រឹះមួយដ៏ល្អមុននឹងឈានទៅចាប់យកជំនាញឌីជីថលនៅកម្រិតមធ្យម និងខ្ពស់។ បន្ថែមពីនេះ ពួកគាត់ក៏អាចកំណត់ពីជំនាញឌីជីថលផ្សេងៗដែលចាំបាច់សម្រាប់ទីផ្សារការងារ ដែលត្រូវសិក្សាស្រាវជ្រាវបន្ថែម ដើម្បីឱ្យពួកគាត់អាចពង្រឹងសមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលនៃតម្រូវការ និងភាពប្រកួតប្រជែងក្នុងទីផ្សារការងារនាពេលបច្ចុប្បន្ននេះ។

#### ការរចនាក្រាហ្វិក

ការរចនាក្រាហ្វិកបាននិងកំពុងក្លាយជាជំនាញមួយ ដែលមានតម្រូវការខ្ពស់នៅក្នុងទីផ្សារការងារកម្ពុជា។ ជំនាញនេះ គឺជាសិល្បៈ ឬវិជ្ជាជីវៈ នៃការបង្ហាញ ដែលរួមបញ្ចូលរូបភាព, អក្សរ និងគំនិត ដើម្បីបញ្ជូនព័ត៌មានដល់ទស្សនិកជន។ ការរចនាក្រាហ្វិកនេះផងដែរ គឺជាជំនាញឌីជីថលដែលមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការប្រកបអាជីវកម្ម ជាពិសេស ស្ថាប័នឯកជន។ សម្រាប់វិស័យពាណិជ្ជកម្ម ការរចនាក្រាហ្វិកបានជួយដល់មុខជំនួញជាច្រើនឱ្យទទួលបានប្រសិទ្ធភាពក្នុងការបញ្ជូនព័ត៌មានឱ្យដល់អ្នកទស្សនា និងគោលដៅអតិថិជន។ យើងសង្កេតឃើញថា តម្រូវការរបស់ក្រុមហ៊ុន និងអាជីវកម្មទាំងអស់មិនថាតូច ឬធំ គឺត្រូវការអ្នករចនាក្រាហ្វិកជាចាំបាច់ ព្រោះថាការរចនាក្រាហ្វិកនេះអាចជួយដល់ការផ្សព្វផ្សាយពាណិជ្ជកម្ម ការធ្វើទីផ្សារ និងការបង្កើត artwork ប្រកបដោយប្រសិទ្ធភាព។ អ្នករចនាក្រាហ្វិកអាចជូនដំណឹង ឬបញ្ចុះបញ្ចូលទស្សនិកជន តាមរយៈការប្រើប្រាស់រូបភាពដែលមានភាពច្នៃប្រឌិតរបស់ពួកគេ។ ជំនាញនេះក៏ជាជំនាញដ៏សាកសមមួយសម្រាប់យុវជន ដែលគាត់មានបំណងចង់ក្លាយជាអ្នកធ្វើការងារឯករាជ្យផងដែរ។

## ជំនាញបណ្ដាញសង្គម

យោងតាមគេហទំព័រ BACKLINKO ក្នុងឆ្នាំ**២០២២** អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមសកម្មមានចំនួនប្រមាណជា **៤,៤៨ ពាន់លាននាក់**នៅទូទាំងសកលលោក។ ក្នុងនោះផងដែរ កម្ពុជាគិតត្រឹមដើមឆ្នាំ**២០២២** ចំនួនអ្នកប្រើប្រាស់បណ្ដាញសង្គមសរុបមានចំនួនប្រមាណជា **១២,៦ លាននាក់**។ តួលេខទាំងនេះបង្ហាញពីការកើនឡើងនៃចំនួនអ្នកប្រើប្រាស់បណ្ដាញសង្គមទូទាំងពិភពលោក ជាពិសេសក្នុងប្រទេសកម្ពុជា គឺមិនមានសញ្ញានៃការថមថយនោះទេ។ ដោយមើលឃើញពីការកើនឡើងនៃចំនួនអ្នកប្រើប្រាស់នេះ បានជំរុញឱ្យអាជីវកម្មជាច្រើនបានជ្រើសរើសបណ្ដាញសង្គម ដើម្បីទំនាក់ទំនងជាមួយអតិថិជនរបស់ពួកគេ និងផ្សព្វផ្សាយផលិតផល និងសេវាកម្មផងដែរ។ ការណ៍នេះ បង្ហាញថាសមត្ថភាពក្នុងការយល់ដឹង និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយប្រសិទ្ធភាព គឺជាជំនាញមួយដែលកំពុងមានតម្រូវការខ្ពស់ ដែលយើងស្គាល់ថាជាជំនាញបណ្ដាញសង្គម។ ជំនាញនេះសំដៅដល់ការប្រាស្រ័យទាក់ទងនៅលើបណ្ដាញសង្គម ការបង្ហោះមាតិកា ការលក់ផលិតផល ការផ្ដល់ជាសេវា និងសកម្មភាពផ្សេងទៀតជាច្រើន។ យុវជនគួរតែចាប់យកឱកាសនេះឈ្វេងយល់ និងសិក្សាបន្ថែមលើមុខងារសំខាន់ៗនានារបស់បណ្ដាញសង្គម ដើម្បីពង្រឹង និងអភិវឌ្ឍន៍សមត្ថភាពបន្ថែមលើជំនាញនេះ។

## ការធ្វើទីផ្សារបែបឌីជីថល

នាពេលបច្ចុប្បន្ន ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម បានផ្លាស់ប្ដូរការធ្វើទំនាក់ទំនងរវាងអាជីវកម្មជាមួយនឹងអតិថិជន និងកែប្រែយុទ្ធសាស្ត្រក្នុងការធ្វើទីផ្សាររបស់អាជីវកម្ម។ អាជីវកម្មអាចទាញយកផលប្រយោជន៍ពីការធ្វើទីផ្សារបែបឌីជីថល តាមរយៈការផ្សព្វផ្សាយផលិតផល និងសេវាកម្មនៅលើបណ្ដាញសង្គម ដូចជា Facebook, Instagram, YouTube និងសារអេឡិចត្រូនិក ដើម្បីបង្កើនការជ្រួតជ្រាបរបស់អតិថិជន ឈានទៅបង្កើនការលក់ផលិតផល និងសេវាកម្ម។ ការធ្វើទីផ្សារបែបឌីជីថល ក៏អនុញ្ញាតឱ្យអាជីវកម្មអាចផ្សារភ្ជាប់អាជីវកម្មជាមួយអតិថិជនដោយផ្ទាល់ បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង រាល់ពេលពួកគេប្រើប្រាស់អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ក្រៅពីការប្រាស្រ័យទាក់ទងជាមួយអតិថិជន ម្ចាស់អាជីវកម្មក៏អាចតាមដានពីប្រសិទ្ធភាពនៃការផ្ដល់សេវា តាមរយៈការឆ្លងឆ្លើយ ការផ្ដល់ជាមតិយោបល់ ជាសារ និងការវាយតម្លៃនៅលើគេហទំព័រ និងបណ្ដាញសង្គមរបស់អាជីវកម្ម ជាដើម។ ការណ៍នេះ បានបង្ហាញពីសារៈសំខាន់នៃការមានជំនាញក្នុងការធ្វើទីផ្សារបែបឌីជីថលសម្រាប់អាជីវកម្ម ដែលធ្វើឱ្យមានតម្រូវការខ្ពស់នូវជំនាញនេះនៅក្នុងទីផ្សារការងារ។ ដូច្នេះ យុវជននៅកម្ពុជាគួរយកចិត្តទុកដាក់លើការចាប់យក និងសិក្សាជំនាញនេះ ដើម្បីមានឱកាសទទួលបានអត្រាការងារខ្ពស់ផងដែរ។

## ការវិភាគទិន្នន័យ

នាពេលបច្ចុប្បន្ន ការវិភាគទិន្នន័យគឺជាជំនាញមួយដ៏សំខាន់បំផុតសម្រាប់ស្ថាប័នរដ្ឋ និងឯកជន។ ទិន្នន័យអាចឱ្យយើងទទួលបាននូវព័ត៌មានដ៏សម្បូរបែប និងអាចឱ្យយើងរៀបចំយុទ្ធសាស្ត្រទីផ្សារប្រកប

ដោយប្រសិទ្ធភាព។ ជំនាញក្នុងវិភាគទិន្នន័យ នេះអាចជួយឱ្យអាជីវកម្មបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ពួកគេ។ ការចេះវិភាគ និងប្រើប្រាស់ទិន្នន័យក្នុងគំរូអាជីវកម្មមានន័យថាក្រុមហ៊ុនអាចកាត់បន្ថយការចំណាយដោយកំណត់យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពជាងមុន។ ក្រុមហ៊ុនក៏អាចប្រើប្រាស់ការវិភាគទិន្នន័យ ដើម្បីធ្វើការសម្រេចចិត្តលើអាជីវកម្មឱ្យបានប្រសើរ និងបំពេញតម្រូវការរបស់អតិថិជនបានល្អជាងមុន។ ដូច្នេះ ការវិភាគទិន្នន័យក៏ជាជំនាញសំខាន់មួយផងដែរ ដែលយុវជនគួរគិតគូរសិក្សា ដើម្បីប្រើប្រាស់ជំនាញនេះជាប្រយោជន៍សម្រាប់បំពេញការងារផ្សេងៗ។

## សន្តិសុខសាយប័រ

បច្ចុប្បន្ននេះ បច្ចេកវិទ្យាឌីជីថលមានការវិវត្តឥតឈប់ឈរ ដែលធ្វើឱ្យសកម្មភាពប្រចាំថ្ងៃរបស់យើងដូចជា ការបំពេញការងារ, ការសិក្សា, ការទំនាក់ទំនង, ការកំសាន្ត សុទ្ធតែត្រូវពឹងផ្អែកលើអ៊ីនធឺណិត។ ទន្ទឹមនឹងការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល ការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិតបានបន្តកើនឡើងជាលំដាប់ដែលធ្វើឱ្យមានការខាតបង់ជាច្រើនផងដែរ ដោយយោងតាមគេហទំព័រ Cybersecurity ការខូចខាតពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតត្រូវបានគេរំពឹងថានឹងកើនឡើងប្រមាណ **១៥%** ក្នុងមួយឆ្នាំក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ដែលឈានដល់ប្រមាណ **១០,៥ ទ្រីលានដុល្លារ** នៅឆ្នាំ**២០២៥** ខាងមុខ។ ដូច្នេះ ការយល់ដឹងពីសន្តិសុខសាយប័រពិតជាមានសារៈសំខាន់សម្រាប់បុគ្គលគ្រប់រូប ដើម្បីបង្ការការខូចខាតដោយសារតែហានិភ័យតាមប្រព័ន្ធអ៊ីនធឺណិត។

## កិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល

សម្រាប់កម្ពុជា, មូលធនមនុស្សទាំងអ្នកដឹកនាំ កម្លាំងពលកម្ម និងប្រជាពលរដ្ឋគ្រប់រូបមានការវិវត្តគួរឱ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹងការចាប់យកឌីជីថល ប៉ុន្តែបើប្រៀបធៀបទៅនឹងបណ្ដាប្រទេសនៅក្នុងតំបន់យើងមើលឃើញថានៅមានកម្រិតនៅឡើយ។ យ៉ាងណាក៏ដោយ យើងសង្កេតឃើញថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ ដោយបានធ្វើការដាក់ចេញនូវគោលនយោបាយ, យុទ្ធសាស្ត្រ និងវិធានការសំខាន់ៗ ដូចជា ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា ២០២១-២០២៥, គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥, វគ្គសិក្សាជំនាញឌីជីថលចាំបាច់របស់ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា, និងអាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ «Techo Digital Talent Scholarship» ជាដើម។ បន្ថែមពីនេះទៀត អង្គការក្រៅរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក៏បានរួមយ៉ាងសំខាន់ ដើម្បីលើកស្ទួយដល់ការពង្រឹងជំនាញឌីជីថលនៅកម្ពុជាទាំងសម្រាប់សាធារណជនទូទៅ, មន្ត្រីរាជការ, ម្ចាស់អាជីវកម្ម, បុគ្គលិកបម្រើការងារឯកជន និងសិស្សានុសិស្ស។

## ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា ២០២១-២០២៥

រដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវ **ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា ២០២១-២០២៥**។ រាជរដ្ឋាភិបាលបានដាក់ចេញនូវសសរស្ដម្ភ

សំខាន់ៗចំនួន ៣ រួមមាន៖ ទី១.ការកសាងពលរដ្ឋឌីជីថល, ទី២. ការកសាងរដ្ឋាភិបាលឌីជីថល និង ទី៣. ការជំរុញធុរកិច្ចឌីជីថល។ ក្នុងនោះ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការ ដោយផ្ដោតលើការអភិវឌ្ឍចំណេះដឹងនិងជំនាញឌីជីថល និងផ្ដល់អាទិភាពលើមុខព្រួញជាក់លាក់ចំនួន ៣ រួមមាន ភាពជាអ្នកដឹកនាំឌីជីថល, បណ្ដុំមូលធនមនុស្សដែលមានទេពកោសល្យឌីជីថល និងពលរដ្ឋឌីជីថល ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន និងជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន តាមរយៈការដាក់ចេញនូវវិធានការដូចជា៖

### ▶ វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល

- រៀបចំក្របខ័ណ្ឌរួមស្ដីពីការលើកកម្ពស់អក្ខរកម្មឌីជីថលក្នុងចំណោមអ្នកដឹកនាំ និងមន្ត្រីនៅតាមក្រសួងស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងការបណ្ដុះបណ្ដាលជំនាញ និងការកសាងនូវភាពជាអ្នកដឹកនាំឌីជីថល
- រៀបចំផែនការរយៈពេលខ្លី និងមធ្យមសម្រាប់ការជំរុញការចាប់យក និងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងការចាត់ចែងការងារព្រមទាំងការលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញឌីជីថល និងភាពជាអ្នកដឹកនាំឌីជីថលនៅក្នុងវិស័យឯកជន។

### ▶ វិធានការគោលនយោបាយបណ្ដុំធនធានមនុស្សមានទេពកោសល្យឌីជីថល

- ការបង្កើតធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិស្ដីពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញឌីជីថល ដោយធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់ឱ្យបានជាក់លាក់អំពីបរិមាណ និងប្រភេទជំនាញឌីជីថលដែលមានតម្រូវការក្នុងទីផ្សារបច្ចុប្បន្ន និងពេលអនាគត
- កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការជំរុញការសិក្សា ការបណ្ដុះបណ្ដាល និងការកសាងជំនាញឌីជីថល នៅថ្នាក់ឧត្តមសិក្សា និងនៅគ្រប់កម្រិតបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងកែលម្អកម្មវិធីសិក្សា ដើម្បីបន្ស៊ីគ្នារវាងតម្រូវការជំនាញ និងការបណ្ដុះបណ្ដាល
- រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និងការបណ្ដុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី ទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន
- រៀបចំយន្តការលើកទឹកចិត្ត គាំទ្រ និងផ្ដល់ភាពងាយស្រួលដល់វិស័យឯកជន ក្នុងការផ្ដល់វគ្គបណ្ដុះបណ្ដាលដល់កម្មករនិយោជិត លើជំនាញឌីជីថល ឬការផ្លាស់ប្ដូរជំនាញទៅចាប់យកជំនាញឌីជីថល។

### ▶ វិធានការគោលនយោបាយផ្នែកពលរដ្ឋឌីជីថល

- កែលម្អប្រព័ន្ធកម្មវិធីសិក្សា ដោយដាក់បញ្ចូលការសិក្សាផ្នែកបច្ចេកវិទ្យាឌីជីថល ជាមុខវិជ្ជាគោលមួយនៅគ្រប់កម្រិត និងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈគ្រប់កម្រិត
- រៀបចំផែនការផ្ដល់មគ្គុទេសក៍ជំនាញ និងអាជីពឌីជីថល នៅគ្រប់កម្រិតអប់រំ និងកម្រិតបណ្ដុះបណ្ដាល ព្រមទាំងបញ្ជ្រាបការយល់ដឹង និងការបំពាក់បំប៉នចំណេះដឹង និងជំនាញឌីជីថលសម្រាប់ការអប់រំក្រៅប្រព័ន្ធ ដើម្បីជំរុញការចាប់យកឌីជីថលប្រកបដោយបរិយាបន្នកម្ម។

## គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥

នៅក្នុងគោលដៅយុទ្ធសាស្ត្រទី ៧ «**ការកសាងមូលធនមនុស្សឌីជីថល**» ចាប់ផ្តើមពីការកសាងសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន សម្រាប់ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលឌីជីថល ដើម្បីធ្វើការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ការលើកកម្ពស់អក្ខរកម្មឌីជីថលដល់សិស្ស និស្សិត និងប្រជាពលរដ្ឋ ក្នុងការជំរុញការទទួលយក និងការប្រើប្រាស់បច្ចេកវិទ្យា ការកាត់បន្ថយគម្លាតឌីជីថល បង្កើនភាពប្រកួតប្រជែង និងការប្រើប្រាស់នូវសេវារដ្ឋាភិបាលឌីជីថល។ រាជរដ្ឋាភិបាលបានដាក់ចេញនូវសកម្មភាពអាទិភាព ដូចជា៖

- ការជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសមន្ត្រីបង្គោលបច្ចេកវិទ្យា សម្រាប់បម្រើដល់ការអភិវឌ្ឍ ការគ្រប់គ្រង ការប្រើប្រាស់ និងការបម្រើសេវាសាធារណៈ។
- រៀបចំក្របខ័ណ្ឌសមត្ថភាពឌីជីថលជាតិ ដែលកំណត់ស្តង់ដាគុណវុឌ្ឍិ សមត្ថភាពនិងជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍រដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចនិងសង្គមឌីជីថល និងឧស្សាហកម្មទី ៤។
- ពង្រឹងនិងពង្រីកគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំកម្មវិធីសិក្សា ការរៀបចំមន្ទីរពិសោធន៍ និងការបណ្តុះបណ្តាលគ្រូបង្គោល រួមមានការពង្រឹងសមត្ថភាពជំនាញ និងវិធីសាស្ត្របង្រៀនបែបឌីជីថល ដើម្បីគាំទ្រដល់ការកសាងមូលធនជំនាញឌីជីថល ដែលមានសមត្ថភាព និងមានភាពប្រកួតប្រជែងខ្ពស់។
- រៀបចំកម្មវិធីតម្រង់ទិសផ្សព្វផ្សាយ ជំរុញ និងលើកទឹកចិត្តដល់យុវជនជាពិសេសយុវនារី ឱ្យចាប់យក និងជ្រើសរើសការសិក្សាជំនាញបច្ចេកវិទ្យាឌីជីថលកាន់តែច្រើន ដើម្បីបង្កើនអ្នកជំនាញឌីជីថលក្នុងទីផ្សារការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយគម្លាតយេនឌ័រជំនាញឌីជីថល។
- ជំរុញការបណ្តុះបណ្តាលជំនាញឌីជីថលសំខាន់ៗ ដូចជា ការអភិវឌ្ឍ software, ទូរគមនាគមន៍ និងបណ្តាញ, បញ្ញាសិប្បនិម្មិត, វិទ្យាសាស្ត្រទិន្នន័យ, និម្មាបនកម្មប្រព័ន្ធព័ត៌មាន, និងសន្តិសុខសាយប័រ តាមរយៈកម្មវិធីអាហារូបករណ៍ និងកម្មវិធីលើកទឹកចិត្តគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការជំនាញនៃការអភិវឌ្ឍឧស្សាហកម្មទី ៤។

## បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT)

បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបចំ **"វគ្គសិក្សាជំនាញឌីជីថលចាំបាច់"** ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពឌីជីថលរបស់មន្ត្រីរាជការ ដើម្បីបម្រើដល់ការអភិវឌ្ឍ, ការគ្រប់គ្រង, ការប្រើប្រាស់ និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព សុវត្ថិភាព និងស័ក្តិសិទ្ធិភាព ដែលនេះជាការចូលរួមចំណែកអនុវត្ត **គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល**

**នៅកម្ពុជា ២០២១-២០២៥** និងជាការអនុវត្តស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** ដែលជានិច្ចជាកាលតែងតែឱ្យតម្លៃលើការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

### ➤ អាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ «Techo Digital Talent Scholarship»

ក្រោមការគិតគូរយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបន្តផ្តល់ជូននូវអាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ **«Techo Digital Talent Scholarship»** ដើម្បីផ្តល់ឱកាសដល់មូលធនមនុស្សដែលមានសមត្ថភាពនិងទេពកោសល្យ និងបង្កើនអ្នកជំនាញបច្ចេកវិទ្យាឌីជីថលក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថល រដ្ឋាភិបាលឌីជីថល និងបដិវត្តន៍ឧស្សាហកម្មទី ៤។

## ➤➤ ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការជំរុញជំនាញឌីជីថលនៅកម្ពុជា

### ➤ មជ្ឈមណ្ឌលកម្ពុជា ៤.0

ក្រសួងទេសចរណ៍ និងសហភាពសហព័ន្ធយុវជនកម្ពុជា បានសហការជាមួយមជ្ឈមណ្ឌលកម្ពុជា ៤.0 បាននិងកំពុងបន្តរៀបចំ ***«វគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា»*** និង ***«វគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលសម្រាប់វិស័យទូទៅ»*** ដែលរួមមានអក្ខរកម្មមូលដ្ឋាន និងអក្ខរកម្មជំនាញ ដោយផ្តោតលើប្រធានបទដែលមានសារៈសំខាន់សម្រាប់ការបំពេញការងារ និងការប្រកបអាជីវកម្ម។ កម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនេះនឹងចូលរួមអភិវឌ្ឍន៍ចំណេះ និងជំនាញឌីជីថលសម្រាប់បុគ្គលិកឯកជន ម្ចាស់អាជីវកម្ម ក៏ដូចជាមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅឆ្លើយតបនឹងតម្រូវការនៃការប្រើប្រាស់នូវបច្ចេកវិទ្យា។

មជ្ឈមណ្ឌលកម្ពុជា ៤.0 បាននិងកំពុងបន្តផ្សព្វផ្សាយវីដេអូអក្ខរកម្ម (E-learning) ស្តីពីការប្រើប្រាស់បច្ចេកវិទ្យា ក៏ដូចជាការប្រើប្រាស់នូវថ្នាលឌីជីថលសំខាន់សម្រាប់អាជីវកម្ម និងបុគ្គលិកទូទៅក្នុងការអភិវឌ្ឍចំណេះ ក៏ដូចជាជំនាញផ្ទាល់ខ្លួន, រួមជាមួយនឹងការរៀបចំកម្មវិធី **"ជជែកពីកម្ពុជា ៤.0"** ដើម្បីចូលរួមបញ្ជ្រាបការយល់ដឹង ពង្រឹងសមត្ថភាព ប្រជាពលរដ្ឋ និងយុវជន ឈានទៅការបង្កើនផលិតភាព ប្រសិទ្ធភាពការងារ និងអាជីវកម្ម។ លើសពីនេះទៅទៀត មជ្ឈមណ្ឌលកម្ពុជា ៤.0 ក៏បានរៀបចំចងក្រង ***«ឯកសារសិក្សាស្រាវជ្រាវអំពីសេដ្ឋកិច្ច-សង្គមឌីជីថល»*** ដោយផ្តោតលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញជាប្រចាំ ដែលផ្តល់ភាពងាយស្រួលដល់សាធារណជនក្នុងការឈ្វេងយល់ និងចែករំលែកបន្តបានគ្រប់ពេល ព្រមទាំងអាចរក្សាទុកមើលបានដោយឥតគិតថ្លៃ ហើយក៏មានការតម្កល់សៀវភៅកម្រងអត្ថបទសិក្សាទាំងនេះ ទុកផ្សព្វផ្សាយនៅតាមបណ្ណាល័យនៅតាមស្ថាប័ន និងសាកលវិទ្យាល័យផងដែរ។




### USAID Digital Workforce Development Project

គម្រោងអភិវឌ្ឍន៍កម្លាំងពលកម្មឌីជីថលរបស់ USAID បង្កើតឡើងក្នុងគោលបំណងជួយយុវជនកម្ពុជាក្នុងការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចឌីជីថល ដើម្បីបំពេញគម្លាតជំនាញឌីជីថល តាមរយៈការកែលម្អ និងពង្រឹងគុណភាពនៃកម្មវិធីសិក្សា និងវគ្គសិក្សាទាក់ទងនឹងជំនាញឌីជីថល និងពង្រឹងជំនាញទន់ ដែលជាកត្តាសំខាន់សម្រាប់ទីផ្សារការងារដែលត្រូវការកម្លាំងពលកម្មជំនាញឌីជីថល។

## IV. សន្និដ្ឋាន

ការដែលមានជំនាញឌីជីថលបានក្លាយជាភាពចាំបាច់មួយសម្រាប់មនុស្សគ្រប់រូប ក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃតម្រូវការទីផ្សារការងារនៅក្នុងយុគសម័យឌីជីថលនេះ។ ជាមួយជំនាញឌីជីថលទាំង ៣ កម្រិត រួមមានជំនាញឌីជីថលកម្រិតមូលដ្ឋាន, មធ្យម និងខ្ពស់ បានអនុញ្ញាតឱ្យយើងទាំងអស់គ្នាអាចទទួលបានអត្រាការងារខ្ពស់, ទទួលបានការងារដែលមានប្រាក់ខែល្អ, រក្សានិរន្តរភាពការងារ និងអាចប្រើប្រាស់ជំនាញទាំងនោះមកចាប់ផ្តើម ឬពង្រីកអាជីវកម្មបន្ថែមផងដែរ។ ដោយឡែកនៅកម្ពុជាយើងសង្កេតឃើញថា ជំនាញឌីជីថលហាក់នៅមានកម្រិតនៅឡើយ ដែលទាមទារចាំបាច់ឱ្យមានការរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមទៅលើជំនាញឌីជីថលសំខាន់ៗ ដូចជា ជំនាញឌីជីថលកម្រិតមូលដ្ឋាន, ការរចនាក្រាហ្វិក, ជំនាញបណ្តាញសង្គម, ការធ្វើទីផ្សារបែបឌីជីថល, ការវិភាគទិន្នន័យ និងសន្តិសុខសាយប័រជាដើម។ ទន្ទឹមនេះ ដើម្បីជំរុញការកសាងសេដ្ឋកិច្ច សង្គមឌីជីថលនៅកម្ពុជា រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ បាននិងកំពុងជំរុញ និងលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថលជូនទៅដល់សាធារណជនទូទៅ បុគ្គលិករដ្ឋ និងបុគ្គលិកឯកជន តាមរយៈការដាក់ចេញនូវគោលនយោបាយ, ផែនការយុទ្ធសាស្ត្រ, វិធានការ និងគម្រោងសំខាន់ៗផងដែរ។ កិច្ចការទាំងនេះក៏ទាមទារឱ្យមានការចូលរួមពីសាធារណជនទូទៅ ម្ចាស់អាជីវកម្ម ម្ចាស់ក្រុមហ៊ុន និងស្ថាប័នរដ្ឋត្រូវគិតគូរវិនិយោគបន្ថែមលើការបណ្តុះបណ្តាលជំនាញទៅដល់បុគ្គលិក។ ជាមួយគ្នានេះដែរ បុគ្គលិក និងសាធារណជនទូទៅក៏ត្រូវខិតខំសិក្សាជំនាញឌីជីថលបន្ថែម ដើម្បីអភិវឌ្ឍន៍ និងពង្រឹងជំនាញរបស់ខ្លួន, បង្កើនប្រសិទ្ធភាពការងារ និងចូលរួមចំណែកក្នុងការកសាងសេដ្ឋកិច្ច សង្គមឌីជីថលនៅកម្ពុជា៕

# ឯកសារយោង


- What Are Digital Skills?, ចេញផ្សាយថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២, ចូលអានថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣, https://digitalskills.unlv.edu/digital-marketing/what-are-digital-skills/#:~:text=Digital%20skills%20are%20defined%20as,such%20as%20computers%20and%20smartphones.
- What Are Digital Skills & Why Are They Important?, ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២, ចូលអានថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣, https://www.linkedin.com/pulse/what-digital-skills-why-important-rto-managing-director/?trk=pulse-article_more-articles_related-content-card
- 5 REASONS WHY YOU NEED DIGITAL SKILLS, ចេញផ្សាយថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០, ចូលអានថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣, https://digitalskillsacademyng.com/5-reasons-why-you-need-digital-skills/
- The Importance of Digital Skills in the Modern Workplace, ចូលអានថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣, https://www.skillsyouneed.com/rhubarb/digital-skills-modern-workplace.html
- What is the Importance of Digital Skills in the Workplace?, ចេញផ្សាយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២, ចូលអានថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣, https://www.highspeedtraining.co.uk/hub/digital-skills-for-the-workplace/
- 10 Digital Skills That Can Make Students Instantly Employable in 2023, ចេញផ្សាយថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣, https://digitalmarketinginstitute.com/blog/10-digital-skills-that-can-make-students-instantly-employable
- The Top 10 Digital Skills Tech Companies are Looking for Today, ចូលអានថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣, https://digitalskillsglobal.com/blog/the-top-10-digital-skills-tech-companies-are-looking-for-today
- Top 5 Digital Skills You'll Need in 2021 (and Possibly in 2022 Too), ចូលអានថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣, https://content.mycareersfuture.gov.sg/top-5-digital-skills-need-2021/
- Top Best Digital Skills to Learn in 2023-2024, ចេញផ្សាយថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣, https://www.gistlibrary.com/top-best-digital-skills-to-learn-in-2023-2024/
- Ministry plots path to 'Digital Cambodia', ចេញផ្សាយថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣, https://www.phnompenhpost.com/national/ministry-plots-path-digital-cambodia#:~:text=According%20to%20the%20minister%2C%20about,70%20per%20cent%20do%20not.
- Professional Graphic Designers bring creativity and meaning together, ចេញផ្សាយថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣, https://cambodia.itstep.org/blog/professional-graphic-designers-bring-creativity-and-meaning-together
- 10 Clear Reasons Why You Need Digital Marketing, ចេញផ្សាយថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨, ចូលអានថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣, 10 Clear Reasons Why You Need Digital Marketing [Updated] | Ballantine
- ការអង្កេតស្តីពី "ភាពមិនស៊ីគ្នានៃជំនាញ និងគុណវឌ្ឍន៍ក្នុងប្រទេសកម្ពុជា" ភស្តុតាងពីការអង្កេតពីជំនាញ និងការងាររបស់កម្មករ- និយោជិតឆ្នាំ២០២០, ចេញផ្សាយខែឧសភា ឆ្នាំ២០២១, ចូលអាន ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣,

http://www.nea.gov.kh/bulletin/view.do?condBulletinMngSeq=e46e1a4727b711ea8e118cec4b8e345c

- *Ministries, institutions prep for digital economy shift*, ចេញផ្សាយថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២២, ចូលអានថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣, https://www.phnompenhpost.com/business/ministries-institutions-prep-digital-economy-shift
- *Ministry planning school digital skills push*, ចេញផ្សាយថ្ងៃទី ១១ ខែមករា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣, https://www.phnompenhpost.com/national/ministry-planning-school-digital-skills-push
- *ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា ២០២១-២០៣៥*, ចេញផ្សាយខែឧសភា ឆ្នាំ២០២១, ចូលអានថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ https://gs.mef.gov.kh/document/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/
- *គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥*, ចេញផ្សាយខែមករា ឆ្នាំ២០២២, ចូលអានថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣https://mptc.gov.kh/documents/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99/27902/
- *សេចក្តីជូនដំណឹង ស្តីពី "អាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ – Techo Digital Talent Scholarship"*, ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២, https://mptc.gov.kh/featured-km/27816/
- *ការបិទបញ្ចប់វគ្គ ជំនាញឌីជីថលចាំបាច់ ជូនដល់មន្ត្រីរាជការចំនួន ៥៦៨ រូប*, ចេញផ្សាយថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២, ចូលអានថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣, https://www.cadt.edu.kh/km/news-km/the-completion-of-digital-skill-essential-course-for-568-civil-servants/
- *A $15m Cash Injection Aims to Bridge Cambodia's Digital Skills Gap*, ចេញផ្សាយថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣, https://kiripost.com/stories/a-15m-loan-aims-to-bridge-cambodias-digital-skills-gap

---

កម្ពុជា ៤.0 - Cambodia 4.0

www.cambodia4point0.org

កម្ពុជា ៤.0 Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center

វិបុលភាព បរិយាប័ន្ន សុវត្ថិភាព